**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង**
**អំពើជួញដូរមនុស្ស**

លេខៈ ០៧៣/១៨ ស.ស.រ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារព័ត៌មានវិទ្យា នៃអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌនគរបាលជាតិកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៤/៨០៨ ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- បានឃើញអនុក្រឹត្យលេខ២៧៣អនក្រ ចុះថ្ងៃទី ០៧ ខែតុលា ឆ្នាំ ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- ផ្អែកតាមសំណូមពរចាំបាច់របស់អគ្គលេខាធិការដ្ឋាន

**ប្រការ១ ៖** បង្កើតក្រុមការងារព័ត៌មានវិទ្យា នៃអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រួមមានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| - លោកជំទាវ | រ៉ែន សិរីលក្ខិណា | អគ្គលេខាធិការរង | ប្រធាន |
| - លោកវរសេនីយ៍ឯក | អ៊ិន មាន | ប្រធានស្តីទីក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |
| - លោកវរសេនីយ៍ទោ | អ៊ឹង ហាក់លៀង | នាយការិយាល័យស្រាវជ្រាវព័ត៌មាន និងត្រួតពិនិត្យ | អនុប្រធាន |
| - លោកស្រីវរសេនីយ៍ត្រី | គុណ កែវរស្មី | នាយរងការិយាល័យស្រាវជ្រាវព័ត៌មាន និងត្រួតពិនិត្យ | អនុប្រធាន |
| - លោកវរសេនីយ៍ត្រី | សៅ ស៊ីនួន | នាយរងការិយាល័យអប់រំផ្សព្វផ្សាយ | សមាជិក |
| - លោកអនុសេនីយ៍ឯក | ជា ពិសិដ្ឋ | មន្ត្រីការិយាល័យរដ្ឋបាល | សមាជិក |
| - លោកអនុសេនីយ៍ត្រី | ធន ដារ៉ាវិទ្ធ | មន្ត្រីក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| - កញ្ញាអនុសេនីយ៍ត្រី | អុន កណ្ណិកា | មន្ត្រីក្រុមជំនួយកិច្ចការយុត្តិធម៌ | សមាជិកា |
| - លោកស្រីអនុសេនីយ៍ត្រី | ថោង សុបុទុម | មន្ត្រីក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ | សមាជិកា |
| - លោកអនុសេនីយ៍ឯក | សេង សុភ័ក្រ្ត | មន្ត្រីក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍ | សមាជិក |
| - លោកអនុសេនីយ៍ត្រី | យុន សុខា | មន្ត្រីក្រុមជំនួយកិច្ចការអនុវត្តច្បាប់ | សមាជិក |
| - លោកអនុសេនីយ៍ត្រី | នន់ ឧត្តម | មន្ត្រីក្រុមជំនួយកិច្ចការការពារជនរងគ្រោះ | សមាជិក |

**ប្រការ២ ៖** ក្រុមការងារព័ត៌មានវិទ្យា នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ មានភារកិច្ចដូចតទៅ ៖

- ដឹកនាំការអភិវឌ្ឍទម្រង់ និងព័ត៌មានក្នុងគេហទំព័រផ្លូវការណ៍របស់ គ.ជ.ប.ជ ដែលការិយាល័យស្រាវជ្រាវព័ត៌មាន និងត្រួតពិនិត្យទទួលបន្ទុកអភិវឌ្ឍ Software និងការិយាល័យអប់រំផ្សព្វផ្សាយទទួលបន្ទុកបញ្ចូលព័ត៌មានប្រចាំថ្ងៃតាមគោលការណ៍ក្រុមការងារព័ត៌មានវិទ្យា
- បង្កើតទម្រង់ និងប្រព័ន្ធរក្សាទុកព័ត៌មាន រូបភាព សកម្មភាព និងឯកសារពាក់ព័ន្ធដែលមានលក្ខណៈងាយស្រួលក្នុងការស្រាវជ្រាវសម្រាប់ក្រុមជំនួយកិច្ចការទាំង៦ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ប្រើប្រាស់រួម
- គ្រប់គ្រង Facebook Page ផ្លូវការណ៍របស់ គ.ជ.ប.ជ
- រៀបចំគោលការណ៍ព័ត៌មានវិទ្យាសម្រាប់អគ្គលេខាធិការដ្ឋានរួមមាន ផែនការសន្តិសុខព័ត៌មាន ផែនការអភិវឌ្ឍព័ត៌មានវិទ្យា Software និង Hardware
- សមាជិក សមាជិកានីមួយៗមានតួនាទីផ្សព្វផ្សាយ និងបង្រៀនបន្តទៅកាន់ក្រុមការងារ និងការិយាល័យរបស់ខ្លួន
- ចូលរួមសហការបង្កើត Database System ដើម្បីរក្សាទុកទិន្នន័យរបាយការណ៍របស់ គ.ជ.ប.ជ
- កោះប្រជុំ និងប្រជុំតាមការអញ្ជើញរបស់លោកប្រធាន ឬអនុប្រធានក្រុមការងារ
- ក្រុមការងារព័ត៌មានវិទ្យាមានសិទ្ធិក្នុងការលើកសំណើលើកទឹកចិត្តផ្សេងៗជូនសមាជិករបស់ខ្លួន
- អនុវត្តតាមការងារផ្សេងៗទៀតដែលប្រធានក្រុមការងារប្រគល់ជូន

**ប្រការ៣ ៖** ការិយាល័យផែនការហិរញ្ញវត្ថុ និងភស្តុភាទទួលបន្ទុកគាំទ្រ និងផ្គត់ផ្គង់គ្រប់មធ្យោបាយនានាដើម្បីដំណើរការការងាររបស់ក្រុមការងារព័ត៌មានវិទ្យាឱ្យមានប្រសិទ្ធភាព ។

**ប្រការ៤ ៖** ក្រុមជំនួយកិច្ចការបង្ការទប់ស្កាត់ ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍ ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ ក្រុមជំនួយកិច្ចការអនុវត្តច្បាប់ ក្រុមជំនួយកិច្ចការយុត្តិធម៌ ការិយាល័យស្រាវជ្រាវព័ត៌មាននិងត្រួតពិនិត្យ ការិយាល័យសរុបផែនការ ការិយាល័យអប់រំផ្សព្វផ្សាយ ការិយាល័យផែនការហិរញ្ញវត្ថុនិងភស្តុភារ ការិយាល័យរដ្ឋបាល ត្រូវអនុវត្តសេចក្តីសម្រេចនេះអោយមានប្រសិទ្ធភាព ។

**ប្រការ៥ ៖** ប្រធាន អនុប្រធាន សមាជិក និងសមាជិកាក្រុមការងារព័ត៌មានវិទ្យា ត្រូវអនុវត្តតួនាទី និងភារកិច្ចដូចមានចែងក្នុងប្រការ២ នៃសេចក្តីសម្រេចនេះ ។

**ប្រការ៦ ៖** បទបញ្ញត្តិទាំងឡាយដែលផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍៕

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំ ច ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ សីហា ឆ្នាំ២០១៨

**អគ្គលេខាធិការ**

នាយឧត្តមសេនីយ៍.ចៅវង.សំរេត

**<u>ចម្លងជូន</u>**

-លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ

-អគ្គលេខាធិការរង ទទួលបន្ទុកក្រុមជំនួយកិច្ចការទាំង៦

-អគ្គលេខាធិការរង ទទួលបន្ទុកលេខាធិការដ្ឋានរដ្ឋបាលសរុប

"គោរពជូនជ្រាប"

-ឯកសារកាលប្បវត្តិ